ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី បច្ចុប្បន្នភាពស្ថានភាពអ្នកដំណើរតាមនាវាទេសចរណ៍ (Viking Cruise Journey) នៅខេត្តកំពង់ចាម និងករណីវិជ្ជមានវីរុសកូវីដ១៩ រកឃើញ២ករណីថ្មីទៀត នៅរាជធានីភ្នំពេញ

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា គិតត្រឹមម៉ោង១៩:០០យប់ នៃថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ នេះ ក្រសួងសូមធ្វើបច្ចុប្បន្នភាពស្ថានភាពអ្នកដំណើរតាមនាវា Viking Cruise Journey នៅខេត្តកំពង់ចាម និងករណីវិជ្ជមានវីរុសកូវីដ១៩ ចំនួន០២ករណីថ្មីទៀត នៅរាជធានីភ្នំពេញ៖

**ក. បច្ចុប្បន្នភាពស្ថានភាពអ្នកដំណើរតាមនាវា** Viking Cruise Journey **នៅខេត្តកំពង់ចាម ៖**

- ក្រៅពីអ្នកវិជ្ជមានវីរុសកូវីដ១៩ ចំនួន ៣នាក់ អ្នកដំណើរនៅលើនាវា Viking Cruise Journey នៅសល់សរុបចំនួន ៦១នាក់ ដែលមានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ១៩ ត្រូវបានដាក់ឲ្យនៅដាច់ដោយឡែក តាមនីតិវិធីចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅសណ្ឋាគារមួយនៃខេត្តកំពង់ចាម ដោយមានការយកចិត្តទុកដាក់ខ្ពស់បំផុតពីអាជ្ញាធរខេត្ត និងមន្ទីរសុខាភិបាលខេត្តកំពង់ចាម
- ចំណែកឯនាវានោះ ក៏ត្រូវធ្វើការសម្អាតឲ្យបានត្រឹមត្រូវតាមវិធានប្រតិបត្តិស្តង់ដាររបស់អង្គការសុខភាពពិភពលោក
- ដោយមានការស្នើសុំពីស្ថានទូតចក្រភពអង់គ្លេសប្រចាំកម្ពុជា និងដោយសារអ្នកដំណើរជាជនជាតិអង់គ្លេសចំនួន២នាក់ (ស្វាមីនិងភរិយា) ដែលមានវិជ្ជមានវីរុសកូវីដនោះ មានវ័យចំណាស់ ដែលអាចនឹងមានបញ្ហាសុខភាពផ្សេងៗទៀត ស្វាមីនិងភរិយាទាំងពីរនាក់នេះ ត្រូវបានសម្របសម្រួលដោយមន្ទីរសុខាភិបាលខេត្ត និងអាជ្ញាធរខេត្តកំពង់ចាម បញ្ជូនមកមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅល្ងាចថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០។ បច្ចុប្បន្នក្រុមគ្រូពេទ្យនិងអ្នកឯកទេសជំងឺសួតនៃមន្ទីរពេទ្យនេះ កំពុងតាមដាន និងព្យាបាល ទៅតាមស្ថានភាពនៃសុខភាពពួកគាត់ ហើយរហូតមកដល់ម៉ោង១៦:០០រសៀលនៃថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ នេះ ពួកគាត់មិនមានចេញរោគសញ្ញាអ្វីនោះទេ គឺនៅស្ថានភាពធម្មតា។
- ដោយសហការជាមួយអង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ក្រុមការងារក្រសួងសុខាភិបាលដែលមាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងនាយកដ្ឋាន/ផ្នែកពាក់ព័ន្ធ ព្រមទាំងមន្ទីរសុខាភិបាលនិងអាជ្ញាធររាជធានីភ្នំពេញ បានបន្តកិច្ចការស្រាវជ្រាវរកឃើញ៖
    - អ្នកប៉ះពាល់ផ្ទាល់ សរុបចំនួន ៦នាក់ (ស្រី២ ប្រុស៤)៖ ៤នាក់ អវិជ្ជមានវីរុសកូវីដ១៩ និង ២នាក់ ទៀត កំពុងរង់ចាំលទ្ធផលពីមន្ទីរពិសោធន៍នៃវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា

- អ្នកប៉ះពាល់ប្រយោល សរុបចំនួន ១៧៩នាក់ (ស្រី៣៦ ប្រុស១៤៣)៖ អ្នកហានិភ័យមធ្យមចំនួន ៣៥ នាក់ បានធ្វើតេស្តឃើញអវិជ្ជមានវីរុសកូវីដ១៩ទាំងអស់រួចហើយ។

## ខ. ករណីវិជ្ជមានវីរុសកូវីដ១៩ ចំនួន០២ករណីថ្មីទៀត នៅរាជធានីភ្នំពេញ ៖

- ករណីថ្មីចំនួន២នាក់ទៀត (មិនមានពាក់ព័ន្ធទៅនឹងនាវា Wiking Cruise Journey ទេ) គឺ ត្រូវបានរកឃើញវិជ្ជមានវីរុសកូវីដ១៩ លើបុរសជនជាតិកាណាដាអាយុ ៥៩ឆ្នាំ និងបុរសជនជាតិប៊ែលហ្ស៊ិក អាយុ ៣៣ឆ្នាំ នៅរាជធានីភ្នំពេញ (លទ្ធផលចេញនៅវេលាម៉ោង១៦:០០រសៀល នាថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០) ហើយបុរសវិជ្ជមានវីរុសកូវីដ១៩ទាំងពីរនាក់នេះ ត្រូវបានយកមកដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត
- ការងារដែលត្រូវធ្វើបន្ត គឺត្រូវស្រាវជ្រាវរកអ្នកដែលប៉ះពាល់ផ្ទាល់ ឬប្រយោល ជាមួយបុរសជនជាតិកាណាដា និងជនជាតិប៊ែលហ្ស៊ិក វិជ្ជមានវីរុសកូវីដទាំងពីរនាក់នេះ ដែលក្រុមការងារខាងលើកំពុងតែសកម្មធ្វើ។

## គ. ករណី២នាក់ដែលរងចាំលទ្ធផល ជាអ្នកទេសចរចូលសារមន្ទីរទួលស្លែង

- លទ្ធផលទាំង ២នាក់ (ជនជាតិអង់គ្លេស និងមិត្តភ័ក្តិគាត់ ២នាក់ និងជនជាតិចិនម្នាក់) អវិជ្ជមានវីរុសកូវីដ១៩។ ដោយពួកគាត់មិនមានប៉ះពាល់ជាមួយអ្នកមានវីរុសកូវីដ១៩ ពួកគាត់ត្រូវបានគ្រូពេទ្យសន្និដ្ឋានថា ជាករណីគ្រុនផ្តាសាយធម្មតា ក៏ប៉ុន្តែ បានណែនាំឲ្យបន្តធ្វើការតាមដានសុខភាពផ្ទាល់ខ្លួនគាត់ (Self-monitoring) ប្រសិនបើមានបញ្ហាសុខភាពអ្វីនោះ ត្រូវមកជួបជាមួយគ្រូពេទ្យវិញ និងរាយការណ៍ទៅលេខ១១៥។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ព្រមទាំងស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ដែលបានខិតខំបំពេញ ភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព ក៏ដូចជាជួយសម្របសម្រួលដល់អ្នកដំណើរតាមនាវាខាងលើនេះទាំងអស់ ហើយក្រសួងនឹងបន្តកិច្ចសហការជាមួយអាជ្ញាធរ ស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ ជាបន្តទៀត រហូតដល់ប្រតិបត្តិការសុខាភិបាល ត្រូវបានបញ្ចប់។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវឌ្ឍនៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៨៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃសុក្រ ៥រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០